ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥០៧ សហវ.ប្រក

# ប្រកាសរួម

## ស្តីពី

## ការកែសម្រួលប្រការ៤ នៃប្រកាសរួមលេខ ៦៥៨ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់ទឹកប្រាក់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩២/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្ដីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៦៥៨ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីការផ្ដល់រង្វាន់លើកទឹកចិត្តលើការផ្ដល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញប្រកាសរួមលេខ .១៥០៦.... សហវ.ប្រក ចុះថ្ងៃទី២២. ខែធ្នូ..... ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីគោលការណ៍ និងនីតិវិធីផ្ដល់រង្វាន់លើកទឹកចិត្តលើការផ្ដល់សេវាសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការមួយ .‒**

ប្រការ៤ នៃប្រកាសរួមលេខ ៦៥៨ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីការផ្ដល់រង្វាន់លើកទឹកចិត្ត លើការផ្ដល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានធ្វើការកែសម្រួល ដូចតទៅ ÷

**ប្រការ៤ .‒ ថ្មី**

ការផ្ដល់ប្រាក់រង្វាន់ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយទៅនឹងប្រាក់ចំណូលប្រមូលបានពីការផ្ដល់សេវាសាធារណៈ ដែលមានចែងក្នុងឧបសម្ព័ន្ធ ១

និងឧបសម្ព័ន្ធ ២ នៃប្រកាសរួមលេខ ៦៥៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងប្រកាសរួមលេខ ១៥០៦..... សហវ.ប្រក ចុះថ្ងៃទី ២២.. ខែ..ធ្នូ..... ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានបែងចែកដូចខាងក្រោម ÷

ក. ការបែងចែកសម្រាប់រដ្ឋបាលកណ្តាល

ក១. ចំពោះប្រាក់ចំណូលប្រមូលបានពីការលក់សំបុត្រចូលទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ត្រូវបានបែងចែកដូចខាងក្រោម ÷

+ បង់ចូលថវិកាជាតិ ១០% នៃចំណូលប្រមូលបាន
+ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១% នៃចំណូលប្រមូលបាន
+ ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៨៩% នៃចំណូលប្រមូលបាន ក្នុងនោះ ÷
  - ថវិកាចំនួន ៥៩% នៃចំណូលប្រមូលបាន សម្រាប់ប្រើប្រាស់លើគោលដៅប្រាក់រង្វាន់លើកទឹកចិត្ត
  - ថវិកាចំនួន ៣០% នៃចំណូលប្រមូលបាន សម្រាប់ប្រើប្រាស់លើគោលដៅជួសជុលថែទាំអាគារ ហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងយន្តការប្រមូលចំណូលរបស់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

ក២. ចំពោះប្រាក់ចំណូលប្រមូលបានពីការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិ ត្រូវបានបែងចែកដូចខាងក្រោម ÷

+ បង់ចូលថវិកាជាតិ ៧០% នៃចំណូលប្រមូលបាន
+ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១% នៃចំណូលប្រមូលបាន
+ ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ២៩% នៃចំណូលប្រមូលបាន ក្នុងនោះ ÷
  - ថវិកាចំនួន ១៩% នៃចំណូលប្រមូលបាន សម្រាប់ប្រើប្រាស់លើគោលដៅប្រាក់រង្វាន់លើកទឹកចិត្ត
  - ថវិកាចំនួន ១០% នៃចំណូលប្រមូលបាន សម្រាប់ប្រើប្រាស់លើគោលដៅជួសជុលថែទាំអាគារ ហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងយន្តការប្រមូលចំណូលរបស់សារមន្ទីរជាតិ។

ក៣. ចំពោះប្រាក់ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ នៅផ្នែកទី III. ផ្នែកសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ ត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ៥០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៤៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១% នៃចំណូលដែលប្រមូលបាន។

ក៤. ចំពោះប្រាក់ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ លើកលែង (ផ្នែកទី I. ផ្នែកសារមន្ទីរ) ការលក់សំបុត្រចូលទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (ចំណុច ក១), ការលក់សំបុត្រចូលទស្សនាសារមន្ទីរជាតិ (ចំណុច ក២) និងផ្នែកទី III. ផ្នែកសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ (ចំណុច ក៣) ត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ៧០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ២៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១% នៃចំណូលដែលប្រមូលបាន។

ខ. ការបែងចែកសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត

ចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដែលមានចែងក្នុងឧបសម្ព័ន្ធ២ ត្រូវបានបែងចែកដូចខាងក្រោម ÷

- បង់ចូលថវិកាជាតិ ៧០% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ២៩% នៃចំណូលដែលប្រមូលបាន
- ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ១% នៃចំណូលដែលប្រមូលបាន។

**ប្រការពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ភឿង-សកុណា**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ